# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- អត្រានៃឥណទានមិនដំណើរការ ធ្លាក់ចុះនៅត្រឹម១% នៅឆ្នាំ២០១៨
- អតិរេកពាណិជ្ជកម្មចិន មានកម្រិតលើសពីការរំពឹងទុករបស់ទីផ្សារ ក្នុងខែមករា ឆ្នាំ២០១៩
- អាមេរិកប្រកាសថាឱនភាពធំជាងការរំពឹងទុក ខណៈប្រាក់ចំណូលមានការធ្លាក់ចុះ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះ បណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### អត្រានៃឥណទានមិនដំណើរការ ធ្លាក់ចុះនៅត្រឹម១% នៅឆ្នាំ២០១៨

បើយោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា អត្រាឥណទានមិនដំណើរការរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ បានធ្លាក់ចុះមកត្រឹម១% ក្នុងឆ្នាំ២០១៨ ដែលអត្រានេះគឺ២% ក្នុងឆ្នាំ២០១៧។ ឥណទានមិនដំណើរការ ត្រូវបានចាត់ថ្នាក់ជាប្រាក់កម្ចីដែលការទូទាត់សងត្រលប់មកវិញមានរយៈពេលហួសកាលកំណត់លើសពី៣០ថ្ងៃ។

ចំនួនអ្នកខ្ចីដែលមិនទាន់សងត្រលប់មកវិញ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានចំនួន១,៨លាននាក់ នៅចុងឆ្នាំ២០១៨។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានសរុបប្រមាណ ៥,៨ប៊ីលានដុល្លារ នៅចុងឆ្នាំ២០១៨ និងទទួលប្រាក់បញ្ញើសរុប ចំនួន២,៥ប៊ីលានដុល្លារ។ ឥណទាននៅក្នុងវិស័យកសិកម្ម មានចំនួនស្មើនឹង៣០% នៃកម្ចីសរុប ។

មូលហេតុដែលនាំអោយឥណទានមិនដំណើរការ មានអត្រាទាបដូចនេះ ត្រូវបានសន្មតថាបណ្តាលមកពីការកើនឡើងនៃតម្លៃផលិតផលកសិកម្មករណីគ្រោះមហន្តរាយធម្មជាតិតិចតួច និងការកើនឡើងនៃការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី។ បើធៀបទៅនឹងបណ្តាប្រទេសអាស៊ានដទៃទៀត អត្រា១%នេះ ត្រូវបានចាត់ទុកថាមានកម្រិតទាប និងអាចគ្រប់គ្រងបាន។

### តារាងប្រចាំសប្តាហ៍៖ ការនាំចេញរបស់តំបន់សេដ្ឋកិច្ចពិសេស តាយសេង-បាវិត

ក្រាហ្វិកនាសប្តាហ៍នេះ ពិពណ៌នាអំពីតម្លៃសរុបនៃការនាំចេញរបស់តំបន់សេដ្ឋកិច្ចពិសេស តាយសេង-បាវិត នៅក្នុងខែមករាឆ្នាំ២០១៨ ធៀបនឹងខែមករា ឆ្នាំ២០១៩។

ការនាំចេញរបស់តាយសេង-បារិត(គិតជាលានដុល្លារ)




ប្រភព៖ [ក្រសួងពាណិជ្ជកម្ម]

ការនាំចេញបានកើនឡើងពី ១៩,៩លានដុល្លារអាមេរិចនៅក្នុងខែមករាឆ្នាំ ២០១៨ ទៅដល់ ២៤,២លានដុល្លារអាមេរិច នៅក្នុងខែមករា ឆ្នាំ២០១៩ ដែលមានកំណើនប្រមាណ២២%។ ទីផ្សារនាំចេញដ៏សំខាន់បំផុតរបស់កម្ពុជា គឺសហភាពអឺរ៉ុប ដែលមានការកើនឡើងខ្ពស់បំផុតផងដែរ គឺចំនួន ២,៤លានដុល្លារអាមេរិច។

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អតិរេកពាណិជ្ជកម្មចិន មានកម្រិតលើសពីការរំពឹងទុករបស់ទីផ្សារ ក្នុងខែមករា ឆ្នាំ២០១៩

បើទោះជាជម្លោះពាណិជ្ជកម្មរវាងចិន-សហរដ្ឋអាមេរិកនៅតែបន្តក៏ដោយ ក៏អតិរេកពាណិជ្ជកម្មរបស់ចិននៅក្នុងខែមករាមានកម្រិតលើសពីការរំពឹងទុករបស់អ្នកសេដ្ឋកិច្ច និង ធ្វើឲ្យអោយទីផ្សារមានការភ្ញាក់ផ្អើលនៅក្នុងសប្តាហ៍នេះ។ ក្រុមអ្នកវិភាគបានធ្វើការព្យាករណ៍ថា អតិរេកពាណិជ្ជកម្មនឹងមានចំនួនត្រឹម ៣៣,៥ប៊ីលានដុល្លារអាមេរិច ប៉ុន្តែលទ្ធផលជាក់ស្តែងអតិរេកបានកើនទៅដល់ ៣៩,១៦ប៊ីលានដុល្លារអាមេរិច បើយោងតាមទិន្នន័យចេញដោយ[រដ្ឋបាលទូទៅគយ] ប្រទេសចិន។

ការនាំចេញរបស់ចិនត្រូវបានព្យាករណ៍ថាធ្លាក់ចុះ ៣,២% បើធៀបនឹងកំឡុងពេលដូចគ្នានៅឆ្នាំមុន ប៉ុន្តែបែរជាកើនឡើងប្រមាណ ៩,១%ទៅវិញ។

ស្ថានភាពដ៏គួរឲ្យភ្ញាក់ផ្អើលនេះ បានឆ្លុះបញ្ចាំងពីទស្សនវិស័យដ៏ល្អសម្រាប់ទីផ្សារអាស៊ីក្នុងឆ្នាំ២០១៩។ ទំហំនៃការនាំចេញ នាំចូលរបស់ប្រទេសចិនជាមួយប្រទេសដទៃទៀតក្នុងតំបន់អាស៊ី បានកើនឡើងគួរឲ្យកត់សម្គាល់ ដោយឡែកចំពោះការនាំចេញ នាំចូលជាមួយនឹងសហរដ្ឋអាមេរិកមានការធ្លាក់ចុះដូចការរំពឹងទុក។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### អាមេរិកប្រកាសថាឱនភាពធំជាងការរំពឹងទុក ខណៈប្រាក់ចំណូលមានការធ្លាក់ចុះ

រដ្ឋាភិបាល អាមេរិកមានឱនភាពថវិការចំនួន ១៤ប៊ីលានដុល្លារអាមេរិច នៅក្នុងខែធ្នូ បើយោងទៅតាម[ទិន្នន័យ]រតនាគារដែលចេញផ្សាយកាលពីថ្ងៃពុធកន្លងទៅ។ ក្រុមអ្នកវិភាគបានព្យាករណ៍ថាឱនភាពថវិកា មានត្រឹមចំនួន១១ប៊ីលានដុល្លារអាមេរិច។ ការភ្ញាក់ផ្អើលនេះបានកើតឡើងដោយសារតែ ប្រាក់ចំណូលពន្ធបានធ្លាក់ចុះ បន្ទាប់ពីមានការកាត់បន្ថយពន្ធយ៉ាងខ្លាំងក្នុងឆ្នាំ២០១៨។ កំណើនសេដ្ឋកិច្ច និងភាពរឹងមាំនៃទីផ្សារការងារ បានជួយដល់ការបង្កើនចំណូល ប៉ុន្តែនេះអាចជាសញ្ញាដែលថាការកាត់ពន្ធអាចមានឥទ្ធិពលខ្លាំងជាងការរំពឹងទុកពីដំបូង។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ កំណើនផសសរបស់ប្រទេសថៃសម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨ និងអត្រាអតិផរណាខែមករា របស់ប្រទេសជប៉ុន ប្រទេសម៉ាឡេស៊ី និងទីក្រុងហុងកុង។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩</u>

- ទិន្នន័យការកម្ម៉ង់ម៉ាស៊ីន របស់ ជប៉ុន សម្រាប់ខែធ្នូ
- កំណើនផសសរបស់ ថៃ សម្រាប់ត្រីមាសទី៤ និងប្រចាំឆ្នាំ២០១៨
- តុល្យភាពពាណិជ្ជកម្មរបស់ សិង្ហបុរី សម្រាប់ខែមករា

- ទិន្នន័យការលក់រថយន្ត ចិន សម្រាប់ខែមករា

<u>ថ្ងៃអង្គារ ទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩</u>

- តម្លៃនាំចេញ នាំចូលរបស់ កូរ៉េខាងត្បូង សម្រាប់ខែមករា
- សន្ទស្សន៍ Reuters Tankan របស់ ជប៉ុនសម្រាប់ខែកុម្ភៈ
- ទិន្នន័យការដេញថ្លៃសញ្ញាណបណ្ណ (bill) ដែលមានរយៈពេល៣ខែ និង៦ខែ របស់អាមេរិក

<u>ថ្ងៃពុធ ទី២០ ខែកុម្ភៈ ឆ្នាំ២០១៩</u>

- តុល្យភាពពាណិជ្ជកម្មរបស់ជប៉ុន សម្រាប់ខែមករា
- ទិន្នន័យការបញ្ជាទិញផ្នែកសំណង់របស់ជប៉ុន សម្រាប់ខែធ្នូ

<u>ថ្ងៃព្រហស្បតិ៍ ទី២១ ខែកុម្ភៈ ឆ្នាំ២០១៩</u>

- តុល្យភាពពាណិជ្ជកម្មរបស់ថៃ សម្រាប់ខែមករា
- ទិន្នន័យនៃអត្រានិកម្មភាព ដំណាក់កាលដំបូង របស់អាមេរិក ថ្ងៃទី១៦ ខែកុម្ភៈ
- ការសម្រេចចិត្តទៅលើអត្រាការប្រាក់របស់ឥណ្ឌូនេស៊ី
- អត្រានិកម្មភាពរបស់ហុងកុង សម្រាប់ខែមករា

<u>ថ្ងៃសុក្រ ទី២២ ខែកុម្ភៈ ឆ្នាំ២០១៩</u>

- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិតរបស់កូរ៉េខាងត្បូង សម្រាប់ខែមករា
- អត្រាអតិផរណារបស់ជប៉ុន សម្រាប់ខែមករា
- អត្រាអតិផរណារបស់ម៉ាឡេស៊ី សម្រាប់ខែមករា
- អត្រាអតិផរណារបស់ហុងកុង សម្រាប់ខែមករា